**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការបន្ថែមសមាសភាពអនុប្រធាន អនុគណៈកម្មការព័ត៌មាន ផ្សព្វផ្សាយ និងសាងសង់ព្រះបរមរូប

**គណៈកម្មាធិការជាតិរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/១៦៥ ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០៤ ស្ដីពីការតែងតាំង **សម្ដេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីវឌ្ឍនៈ គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០១២/៩៤៦ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១២ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព **ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ**
- បានឃើញ អនុក្រឹត្យលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១២ ស្ដីពីការបង្កើតអនុគណៈកម្មការទទួលភារកិច្ចរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព **ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ**
- យោង សំណូមពរការងារ និងតម្រូវការចាំបាច់ ។

**សម្រេច**

**មាត្រា ១ :** ត្រូវបានតែងតាំង សម្ដេចព្រះឧត្ដមបញ្ញា **ជួន ណាត់** (នន្ទិយោ) ជាអនុប្រធាននៃអនុគណៈកម្មការព័ត៌មានផ្សព្វផ្សាយ និងសាងសង់ព្រះបរមរូប ។

p

www.pheakdeylaw.com

**មាត្រា ២** : ព្រះអង្គដែលមានព្រះនាមក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តតាមអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**មាត្រា ៣** : អនុក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>ចម្លងជូន</u>** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ឯកសារ


www.pheakdeylaw.com